ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២០៦ សហវ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០០៥

# ប្រកាស
## ស្ដីពី
## ការបង្កើត និងដាក់ឱ្យដំណើរការផ្លូវសាខាគយនិងរដ្ឋាករ ក្រុងប៉ៃលិន

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញលិខិតបញ្ជាលេខ ០២ បប ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០០១ ស្ដីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ និងលេខ០២បប ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៤ ស្ដីពីវិធានការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ
- បានឃើញចំណារសម្ដេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៥ លើលិខិតលេខ ០២៥សហវ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្ដីពី វិធានការរយៈពេលខ្លី និងមធ្យម ដើម្បីជំរុញកំណើនចំណូលពន្ធ អាករ ដែលប្រមូលដោយទីចាត់ការគយនិងរដ្ឋាករ ក៏ដូចជាចំណូលសារពើពន្ធ ។
- យោងតាមសំណូមពរការងារចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពនៃការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ

## សំរេច

**ប្រការ ១ :** បង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយនិងរដ្ឋាករ ក្រុងប៉ៃលិន ថ្នាក់ប្រហាក់ប្រហែល មន្ទីរនានាជុំវិញខេត្ត ក្រុង ដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករ នៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានការិយាល័យកណ្តាលបោះប្រចាំនៅក្រុងប៉ៃលិន ។

**ប្រការ ២ :** សាខាគយនិងរដ្ឋាករ ក្រុងប៉ៃលិន ដឹកនាំដោយប្រធានសាខាមួយរូប និងអនុប្រធានមួយចំនួន ជាជំនួយការ ។

**ប្រការ ៣ :** សាខាគយនិងរដ្ឋាករ ក្រុងប៉ៃលិន មានភារកិច្ចដូចតទៅ ៖

១- គ្រប់គ្រង ដឹកនាំបញ្ជាតាមឋានានុក្រមដោយផ្ទាល់លើទីស្នាក់ការគយនិងរដ្ឋាករទាំងអស់ ក្នុង ភូមិសាស្ត្រ ក្រុងប៉ៃលិន និងលើអង្គភាពស្រាវជ្រាវ អង្គភាពចល័ត និងគ្រៀមអន្តរាគមន៍នានា ក្រោមឱវាទ ។

២- ចាត់ចែង រៀបចំ ផ្សព្វផ្សាយតាមរូបភាពនានាដល់អាជីវករ និងបុគ្គលពាក់ពន្ធ័ទាំងឡាយឱ្យ យល់ដឹងទាន់ពេលវេលាពីភាពស្របច្បាប់ នៃទំនិញនាំចូលនិងការទទួលខុសត្រូវចំពោះមុខច្បាប់ រាល់ពេលរកឃើញមានការចូលរួមគេចវេសកាតព្វកិច្ចពន្ធ អាករដោយផ្ទាល់ ឬ ដោយប្រយោល ការធ្វើចរាចរចែកចាយសន្និធិទំនិញនាំចូលដោយល្មើសនានាក្នុងមូលដ្ឋាន អាជីវកម្មដ្ឋាន ឬ លំនៅដ្ឋាននីមួយៗ ។

៣- ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគយនានាក្នុងភូមិសាស្ត្រគ្រប់គ្រងរបស់ក្រុងប៉ៃលិន លើទំនិញនាំចូលដោយគេចពន្ធតាមគ្រប់រូបភាពដែលកំពុងសន្និធិចរាចរ ចែកចាយ ឬកំពុង ប្រើប្រាស់តាមបណ្តាអាជីវកម្មដ្ឋាន ភណ្ឌាគារទំនិញ មូលដ្ឋានផលិតកម្ម ឬលំនៅដ្ឋាននានា ដោយអនុលោមតាមនីតិវិធីច្បាប់ និងបទបញ្ញត្តិនានាជាធរមាន ។

៤- ចុះស្រង់ និងកសាងបញ្ជីជំរឿនស្ថិតិ អាជីវកម្មដ្ឋានលក់ដុំ លក់រាយ ភណ្ឌាគារសន្និធិទំនិញ នានា ដែលស្ថិតក្រោមប្រពន្ធ័គ្រប់គ្រងពិសេស រួមមាន យានយន្តគ្រប់ប្រភេទ ផលិតផល តេលសិលា ភេសជ្ជៈ ព្រមទាំងទំនិញសេរីបមួយចំនួនទៀតដែលនឹងកំណត់ដោយទីចាត់ការ គយនិងរដ្ឋាករ ។

៥- អនុវត្តតាមភារកិច្ចផ្សេងៗដែលនឹងកំណត់តាមការចាំបាច់នានា ដោយទីចាត់ការគយនិងរដ្ឋាករ ស្របតាមបញ្ញត្តិច្បាប់ជាធរមាន ។

៦- ប្រើប្រាស់កំលាំងគយនិងរដ្ឋាករក្រោមឱវាទ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ប្រចាំមូលដ្ឋាន ជាពិសេសអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ក្នុងករណីចាំបាច់ ដើម្បីសំរេចឱ្យបាន នូវភារកិច្ចដូចរៀបរាប់ខាងលើ ។

**ប្រការ ៤ :** ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ពន្ធ័ផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**គាត ឈន់**

<u>ចម្លងជូន</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ ( ដើម្បីជូនជ្រាប )
- សាលាក្រុងប៉ៃលិន
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  ( ដើម្បីជូនជ្រាប និងសុំកិច្ចសហការអនុវត្ត )
- ដូចប្រការ៥ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ